ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៤០៧៤ មស.សជណ

# សេចក្តីជូនដំណឹង

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម សូមជូនដំណឹងដល់បេក្ខជនដែលបានបំពេញសំណុំបែបបទសុំសិទ្ធិប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌ ក្រសួង ស្ថាប័នទាំង៤ ឱ្យបានជ្រាបថា គណៈកម្មការរៀបចំការប្រឡងនឹងធ្វើការបិតផ្សាយបញ្ជីឈ្មោះបេក្ខជនដែលបានបំពេញនូវលក្ខខណ្ឌសមស្របឱ្យចូលរួមប្រឡងក្របខណ្ឌសម្រាប់ឆ្នាំ២០១៨នេះ តាមការកំណត់ដូចខាងក្រោម៖

**១**- សេចក្តីសម្រេចស្តីពីការអនុញ្ញាតឱ្យបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីចូលរួមប្រឡងមានបិតផ្សាយនៅក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម *ចាប់ពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ តទៅ*។

*បេក្ខជន បេក្ខនារី មានសិទ្ធិតវ៉ាមកអនុគណៈកម្មការទទួលពាក្យ និងរៀបចំឯកសារ នៅក្រសួងមុខងារសាធារណៈ ក្នុងករណីមិនមានឈ្មោះប្រឡង ឬបញ្ហាផ្សេងៗ ត្រឹមថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ១៧៖០០ ។*

**២-សម័យប្រឡង៖ ថ្ងៃសៅរ៍ ៣រោច ខែអស្សុជ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨**

**៣-មណ្ឌលប្រឡង៖ វិទ្យាល័យសន្ធរម៉ុក**

**៤-ពេលវេលាប្រឡង៖**

ក. ម៉ោង ០៦:០០នាទី៖ គណៈកម្មការរៀបចំការប្រឡង អនុគណៈកម្មការនានា និងបេក្ខជនត្រូវមកដល់មណ្ឌលប្រឡង

ខ. ម៉ោង ០៦:៣០នាទី ដល់ ម៉ោង ០៦:៥០នាទី៖ អនុរក្សហៅឈ្មោះបេក្ខជនចូលបន្ទប់ ត្រួតពិនិត្យវត្តមាន ប្រកាសបទបញ្ញត្តិ និងចែកសន្លឹកកិច្ចការដល់បេក្ខជន

គ. ម៉ោងទី១ ចាប់ពីម៉ោង ០៧:០០នាទី ដល់ ម៉ោង ៩:០០នាទី

ឃ.ម៉ោងទី២ ចាប់ពីម៉ោង ០៩:៣០នាទី ដល់ ម៉ោង ១១:០០នាទី

**៥-វិញ្ញាសាប្រឡងសម្រាប់ក្រសួង ស្ថាប័ន ត្រូវបានកំណត់ដូចខាងក្រោម៖**

**ក. ក្រសួងមុខងារសាធារណៈ**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**ខ. ក្រសួងយុត្តិធម៌**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងជំនាញ ហិរញ្ញវត្ថុ ឬគណនេយ្យ រយៈពេល ០២ម៉ោង
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី

**គ. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង
- ម៉ោងទី២៖ មុខវិជ្ជាពាក់ព័ន្ធនឹងជំនាញ គ្រប់គ្រង គណនេយ្យ ហិរញ្ញវត្ថុ ឬសង្គមវិទ្យា រយៈពេល ០១ម៉ោង ៣០នាទី

**ឃ. ក្រសួងពាណិជ្ជកម្ម**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង ចំពោះបេក្ខជនប្រឡងជ្រើសរើសមុខវិជ្ជាព័ត៌មានវិទ្យា
- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងជំនាញ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ** ចំពោះបេក្ខជនប្រឡងជ្រើសរើសមុខវិជ្ជា៖

  ១. គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច និងសេដ្ឋកិច្ចព័ត៌មានវិទ្យា

  ២. គណនេយ្យ ហិរញ្ញវត្ថុ និងធនាគារ

  ៣. មគ្គុទេសក៍ទេសចរណ៍
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**

**៦-** ចំពោះ**ប្លង់មណ្ឌលប្រឡង លេខបន្ទប់ និងលេខតុ** របស់បេក្ខជន បេក្ខនារីនឹងធ្វើការបិតផ្សាយនៅវិទ្យាល័យសន្ធរម៉ុក *នាថ្ងៃសុក្រ ទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ១០៖០០នាទីព្រឹក*

អាស្រ័យហេតុនេះ សូមបេក្ខជន បេក្ខនារី ដែលមានឈ្មោះចូលរួមប្រឡង ត្រូវយកមកជាមួយនូវឯកសារដូចជាសលាកប័ត្រឯកត្តជន អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណសំគាល់ខ្លួនសិស្ស និស្សិត ជាដើម។

*បញ្ជាក់៖ គណៈកម្មការរៀបចំការប្រឡង មានសិទ្ធិកែប្រែសេចក្តីជូនដំណឹងនេះ ក្នុងករណីចាំបាច់៕*

ថ្ងៃ ទេស្គ្គារ ១រោច ខែភទ្របទ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១៨

**រដ្ឋលេខាធិការនិងជា**

**អនុប្រធានគណៈកម្មការរៀបចំការប្រឡង**

**ទ៉ាន់ ម៉ារា**

-ឯកសារ កាលប្បវត្តិ